# សេចក្តីសម្រេចលើការណ៍លួច

## (សាលដីកាចុះ**ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៩៤)**

## សំណុំរឿងព្រហ្មទណ្ឌលេខ ១៨ ឆ្នាំ ១៩៩៤

(ISMAIL BIN CHUCHU @ TAIB v. PUBLIC PROSECUTOR)

នាយកដ្ឋានសាធារណៈការ បានធ្វើការកែលម្អជាថ្មី (re-decorating) ចំពោះផ្ទះសំណាក់មួយ (bungalow) ។ នៅក្នុងការកែលម្អនេះ គេបានយកម៉ាស៊ីនត្រជាក់មួយគ្រឿងចេញ ហើយបិទស្នាមប្រហោងលើជញ្ជាំងដោយ បំណែកក្តារបន្ទះមួយ ។ ដើមបណ្តឹងឧទ្ធរណ៍ បានដកយកបំណែកក្តារបន្ទះនោះចេញ ហើយបានចូលទៅក្នុងផ្ទះតាមប្រហោងនោះ ។ បន្ទាប់មក គាត់បានលួចយកថ្នាំលាបចំនួន ១១ កំប៉ុង និងជក់ ចំនួន ៤ ដើម សរុបតម្លៃចំនួន ២២៩.១០ ដុល្លា ។

នៅពេលនោះ ផ្ទះសំណាក់នោះមិនមាននរណាគ្រប់គ្រងឡើយ ។ វត្ថុដែលបានលួច ត្រូវបានយកមកដាក់កន្លែងដើមវិញហើយ ប៉ុន្តែដើមបណ្តឹងឧទ្ធរណ៍ធ្លាប់មានទោសពីរដងហើយ ពីបទលួច ។ គាត់ទទួលថាបានប្រព្រឹត្ត (plead guilty) និងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ១៨ ខែ ។ គាត់បានប្តឹងតវ៉ា នឹងសេចក្តីសម្រេចនេះ ។

ចៅក្រមជំនុំជម្រះ បានយល់ឃើញថា ករណីអំពើលួច នៅក្នុងផ្ទះនោះជាករណីដែលកាន់តែមានច្រើនឡើងៗ (were on the rise) ។ ដើមបណ្តឹងឧទ្ធរណ៍បានទាមទារឲ្យមានការបន្ថយទោស ដោយលើកហេតុផលថា ខ្លួនមានកូន ៥ នាក់ ដែលត្រូវការការមើលថែ និងការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីខ្លួន ហើយ

មិនតែប៉ុណ្ណោះ គាត់ក៏មានជំពាក់ធនាគារ ដែលត្រូវតែរកប្រាក់ដើម្បីសង ផងដែរ ។

នៅក្នុងកាលៈទេសៈណាក៏ដោយ យើងមិនអាចគិតថា ការកាត់ទោសនេះ ធ្ងន់ធ្ងរហួសហេតុនោះទេ ។ ហេតុនេះ ចៅក្រមបានសម្រេចបដិសេធបណ្ដឹងឧទ្ធរណ៍។

ចៅក្រមសាលាឧទ្ធរណ៍ (SIR ALAN HUGGINS)

ប្រធានសាលាឧទ្ធរណ៍ (KUTLUTEKIN FUAD)

ចៅក្រមសាលាឧទ្ធរណ៍ (SIR DEREK CONS)

អ្នកប្ដឹងឧទ្ធរណ៍ និង លោក Zuraini bte Hj Sharbawi តំណាងឲ្យរដ្ឋអាជ្ញា។